ក្រសួងមហាផ្ទៃ

# ប្រកាស

# ស្តីពី

# ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការ ទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់

អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ
ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខៈ ៣៤៤០ ប្រក

# ប្រកាស
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការ ទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការផ្ទេរមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ដើម្បីផ្តល់យោបល់ និងជួយរដ្ឋបាលឃុំ សង្កាត់ក្នុងការសម្របសម្រួល និងការអនុវត្តសកម្មភាពសេវាសង្គមទាំងអស់នៅក្នុងឃុំ សង្កាត់។



ស

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅកំណត់អំពីសមាសភាព តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់។

**ប្រការ ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តនៅគ្រប់រដ្ឋបាលឃុំ សង្កាត់ទូទាំងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## សមាសភាព តួនាទី និងភារកិច្ច

## របស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់

**ប្រការ ៤.-**

ត្រូវបង្កើតឱ្យមានគណៈកម្មាធិការមួយនៅរដ្ឋបាលឃុំ សង្កាត់នៃអាណត្តិក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ដែលមានឈ្មោះថា **គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់** សរសេរជាអក្សរកាត់ថា **គ.ក.ន.ក.**។

**ប្រការ ៥.-**

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់មានសមាសភាពដូចខាងក្រោម ៖

- មេឃុំ ចៅសង្កាត់ ជាប្រធាន
- ជំទប់ទី២ ចៅសង្កាត់រងទី២ ជាអនុប្រធាន
- អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ជាសមាជិកអចិន្ត្រៃយ៍
- ស្មៀនឃុំ សង្កាត់ ជាសមាជិក
- នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ជាសមាជិក
- នាយក ឬនាយិកាសាលាបឋមសិក្សានៅក្នុងឃុំ សង្កាត់០១រូប ជាសមាជិក
- នាយក ឬនាយិកាសាលាមធ្យមសិក្សានៅក្នុងឃុំ សង្កាត់០១រូប ជាសមាជិក
- ប្រធានមណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាព ជាសមាជិក
- មេភូមិ ឬអនុប្រធានភូមិទាំងអស់នៅក្នុងឃុំ សង្កាត់ ជាសមាជិក
- តំណាងក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនឃុំ សង្កាត់០១រូប ជាសមាជិក
- តំណាងសមាគមមនុស្សចាស់០១រូប ជាសមាជិក
- តំណាងជនមានពិការភាព០១រូប ជាសមាជិក
- ជំនួយការសេវាសង្គមឃុំ សង្កាត់ ជាលេខាធិការ

ក្រៅពីសមាសភាពគណៈកម្មាធិការដែលបានកំណត់ខាងលើនេះ មេឃុំ ចៅសង្កាត់អាចបន្ថែមសមាសភាពផ្សេងៗទៀត ទៅតាមស្ថានភាពជាក់ស្តែងនៃឃុំ សង្កាត់របស់ខ្លួន។

ក្នុងករណីជំទប់ទី២ ចៅសង្កាត់រងទី២ ជាស្ត្រី ហើយត្រូវបានតែងតាំងជាអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ និងជាអនុប្រធានគណៈកម្មាធិការ មេឃុំ ចៅសង្កាត់ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មួយរូបផ្សេងទៀត ដែលមានសមត្ថភាព និងបទពិសោធន៍លើកិច្ចការសេវាសង្គម ធ្វើជាសមាជិកអចិន្ត្រៃយ៍នៃគណៈកម្មាធិការ។

មេឃុំ ចៅសង្កាត់អាចប្រគល់សិទ្ធិឱ្យជំទប់ទី២ ចៅសង្កាត់រងទី២ ធ្វើជាប្រធានគណៈកម្មាធិការ។ ក្នុងករណីនេះ មេឃុំ ចៅសង្កាត់ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មួយរូប ដែលមានសមត្ថភាព និងបទពិសោធន៍លើកិច្ចការសេវាសង្គម ធ្វើជាអនុប្រធានគណៈកម្មាធិការ។ ប្រសិនបើសមាជិកក្រុមប្រឹក្សារូបនេះជាស្ត្រី ហើយត្រូវបានតែងតាំងជាអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ និងជាអនុប្រធានគណៈកម្មាធិការ មេឃុំ ចៅសង្កាត់ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មួយរូបផ្សេងទៀត ដែលមានសមត្ថភាព និងបទពិសោធន៍លើកិច្ចការសេវាសង្គម ធ្វើជាសមាជិកអចិន្ត្រៃយ៍នៃគណៈកម្មាធិការ។

ជាគោលការណ៍ ការជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់សម្រាប់ជំនួសមុខតំណែងតាមករណីនីមួយៗដែលបានបរិយាយខាងលើនេះ (មុខតំណែងអនុប្រធានគណៈកម្មាធិការ ឬមុខតំណែងសមាជិកអចិន្ត្រៃយ៍) ត្រូវផ្ដល់អាទិភាពខ្ពស់បំផុតចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី។

មេឃុំ ចៅសង្កាត់ត្រូវសម្របសម្រួលជ្រើសរើសនាយក ឬនាយិកាសាលាបឋមសិក្សាមួយរូប តំណាងឱ្យសាលាបឋមសិក្សាទាំងអស់នៅក្នុងឃុំ សង្កាត់ ជាសមាជិកគណៈកម្មាធិការ។

មេឃុំ ចៅសង្កាត់ត្រូវសម្របសម្រួលជ្រើសរើសនាយក ឬនាយិកាសាលាមត្តេយ្យសិក្សាមួយរូប តំណាងឱ្យសាលាមត្តេយ្យសិក្សាទាំងអស់នៅក្នុងឃុំ សង្កាត់ ជាសមាជិកគណៈកម្មាធិការ។

ចំពោះឃុំ សង្កាត់ដែលពុំមានជំនួយការសេវាសង្គមឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ត្រូវធ្វើជាលេខាធិការគណៈកម្មាធិការ។

ចំពោះឃុំ សង្កាត់ដែលមានជនជាតិដើមភាគតិចរស់នៅ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រជុំសម្រេចអំពីការដាក់បញ្ចូល ឬការមិនដាក់បញ្ចូលតំណាងជនជាតិដើមភាគតិចនៅក្នុងសមាសភាពគណៈកម្មាធិការ។ ក្នុងករណីក្រុមប្រឹក្សាបានសម្រេចដាក់បញ្ចូលតំណាងជនជាតិដើមភាគតិច នៅក្នុងសមាសភាពគណៈ-កម្មាធិការ មេឃុំ ចៅសង្កាត់ត្រូវសម្របសម្រួលជ្រើសរើសតំណាងជនជាតិដើមភាគតិច០១រូបនៃអម្បូរជនជាតិដើមភាគតិចនីមួយៗ ជាសមាជិកគណៈកម្មាធិការ។

តំណាងក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនឃុំ សង្កាត់០១រូប ត្រូវជ្រើសរើស និងចាត់តាំងដោយក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនឃុំ សង្កាត់។

មេឃុំ ចៅសង្កាត់ត្រូវសម្របសម្រួលសមាគមមនុស្សចាស់នៅក្នុងឃុំ សង្កាត់របស់ខ្លួន ដើម្បីជ្រើសរើសតំណាងសមាគមមនុស្សចាស់ចំនួន០១រូប សម្រាប់ធ្វើជាសមាជិកគណៈកម្មាធិការ។

មេឃុំ ចៅសង្កាត់ត្រូវសម្របសម្រួលជ្រើសរើសតំណាងជនមានពិការភាពចំនួន០១រូប នៅក្នុងឃុំ សង្កាត់របស់ខ្លួន សម្រាប់ធ្វើជាសមាជិកគណៈកម្មាធិការ។ តំណាងជនមានពិការភាពត្រូវតែជាជនដែលមានពិការភាព។

ចំពោះឃុំ សង្កាត់ដែលមានរៀបចំចងក្រងបង្កើតឡើងនូវក្រុមកុមារ ឬវេទិកាកុមារ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រជុំសម្រេចអំពីការដាក់បញ្ចូល ឬការមិនដាក់បញ្ចូលតំណាងកុមារនៅក្នុងសមាសភាពគណៈ-កម្មាធិការ។ ក្នុងករណីក្រុមប្រឹក្សាបានសម្រេចដាក់បញ្ចូលតំណាងកុមារនៅក្នុងសមាសភាពគណៈកម្មាធិការ មេឃុំ ចៅសង្កាត់ត្រូវសម្របសម្រួលជ្រើសរើសតំណាងកុមារ០១រូប ជាសមាជិកគណៈកម្មាធិការ។

ដើម្បីលើកកម្ពស់ការចូលរួមរបស់ស្ត្រីនៅក្នុងដំណើរការធ្វើសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវខិតខំដាក់បញ្ចូលសមាសភាពជាស្ត្រីឱ្យបានច្រើននៅក្នុងគណៈកម្មាធិការនេះ។

មេឃុំ ចៅសង្កាត់ត្រូវរៀបចំសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់(**ទម្រង់ទី១**) ដែលកំណត់អំពីសមាសភាព តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់គណៈកម្មាធិការ ហើយដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនដើម្បីពិនិត្យ និងអនុម័ត។ កិច្ចប្រជុំពិនិត្យ និងអនុម័តសេចក្តីព្រាងសេចក្តីសម្រេចនេះត្រូវអនុវត្តតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់សាមី។

បន្ទាប់ពីទទួលបានការអនុម័តពីក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ត្រូវចេញសេចក្តីសម្រេចស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់។

ក្នុងករណីមានការបន្ថែម ឬមានការផ្លាស់ប្តូរសមាសភាពគណៈកម្មាធិការ មេឃុំ ចៅសង្កាត់ត្រូវចេញសេចក្តីសម្រេចជាថ្មីស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ទៅតាមនីតិវិធីដែលបានកំណត់ខាងលើ។

**ប្រការ ៦.-**

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់មានតួនាទីផ្តល់យោបល់ និងជួយរដ្ឋបាលឃុំ សង្កាត់ក្នុងការសម្របសម្រួល និងការអនុវត្តសកម្មភាពសេវាសង្គមទាំងអស់នៅក្នុងឃុំ សង្កាត់ ដើម្បីធានាថា ស្ត្រី កុមារ យុវជន មនុស្សចាស់ ជនក្រីក្រ ជនមានពិការភាព ជនជាតិដើមភាគតិច និងជនងាយរងគ្រោះផ្សេងៗទៀត ទទួលបានព័ត៌មាន ចំណេះដឹង និងសេវានានាប្រកបដោយសមធម៌សង្គម និងបរិយាប័ន្ន ព្រមទាំងមានជីវភាពរស់នៅប្រកបដោយសុវត្ថិភាព សុខដុមរមនា និងសេចក្តីថ្លៃថ្នូរ។

**ប្រការ ៧.-**

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់មានភារកិច្ចដូចខាងក្រោម ៖

- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់អនុវត្តសកម្មភាពសេវាសង្គមនានា ដោយផ្អែកតាមកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ហើយដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យ និងអនុម័ត ដើម្បីដាក់បញ្ចូលទៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់
- សហការ និងសម្របសម្រួលការអនុវត្តសកម្មភាពសេវាសង្គមនានានៅក្នុងឃុំ សង្កាត់ ទៅតាមផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់អនុវត្តសកម្មភាពសេវាសង្គម
- តាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសកម្មភាពសេវាសង្គមនានានៅក្នុងឃុំ សង្កាត់របស់ខ្លួន
- ប្រមូល និងវិភាគទិន្នន័យតាមរយៈដំណើរការរៀបចំ និងធ្វើបច្ចុប្បន្នភាពផែនទីសេវាសង្គម និងឬតាមរយៈការប្រើប្រាស់ឧបករណ៍វិភាគសេវាសង្គមផ្សេងៗទៀត ដើម្បីកំណត់បញ្ហា តម្រូវការ និងដំណោះស្រាយផ្នែកសេវាសង្គម សម្រាប់ដាក់បញ្ចូលទៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់
- ពិនិត្យ និងផ្តល់យោបល់ទៅលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ រួមទាំងសេចក្តីព្រាងវិសោធនកម្មផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ដើម្បីធានាថា បញ្ហា តម្រូវការ ដំណោះស្រាយ និងគម្រោងមួយសកម្មភាពផ្នែកសេវាសង្គមត្រូវបានដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

- ពិនិត្យ និងផ្តល់យោបល់ទៅលើសេចក្តីព្រាងគម្រោងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់ និងសេចក្តីព្រាងកែសម្រួលគម្រោងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់ ដើម្បីធានាថា សកម្មភាពឬគម្រោងអាទិភាពនានាផ្នែកសេវាសង្គម ត្រូវបានវិភាជថវិកាសម្រាប់អនុវត្តប្រកបដោយសមធម៌សង្គម និងបរិយាប័ន្ន
- ផ្តល់ប្រឹក្សាយោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់អំពីកិច្ចការសេវាសង្គមនានានៅក្នុងឃុំ សង្កាត់ ប្រកបដោយសមធម៌សង្គម និងបរិយាប័ន្ន
- គាំទ្រ និងលើកទឹកចិត្តដល់ស្ត្រី កុមារ យុវជន មនុស្សចាស់ ជនក្រីក្រ ជនមានពិការភាព ជនជាតិដើមភាគតិច និងជនងាយរងគ្រោះផ្សេងៗទៀត ឱ្យចូលរួមនៅក្នុងដំណើរការធ្វើសេចក្តីសម្រេច និងដំណើរការអនុវត្តសេចក្តីសម្រេចរបស់រដ្ឋបាលឃុំ សង្កាត់ ដើម្បីអភិវឌ្ឍមូលដ្ឋានប្រកបដោយសមធម៌សង្គម និងបរិយាប័ន្ន
- ចលនា និងជំរុញលើកទឹកចិត្តដល់ប្រជាពលរដ្ឋ ជាពិសេសស្ត្រី កុមារ យុវជន មនុស្សចាស់ ជនក្រីក្រ ជនមានពិការភាព ជនជាតិដើមភាគតិច និងជនងាយរងគ្រោះផ្សេងៗទៀត ឱ្យទៅទទួលយកសេវាសង្គមនានា ព្រមទាំងចូលរួមបង្ការ ទប់ស្កាត់ និងដោះស្រាយបញ្ហាសង្គមនានាដែលកើតមានឡើងនៅក្នុងឃុំ សង្កាត់
- ចលនាអង្គភាពរដ្ឋ អង្គការសង្គមស៊ីវិល និងផ្នែកឯកជន ឱ្យចូលរួមចំណែកយ៉ាងសកម្មក្នុងការរៀបចំស្ថាប័នរបស់ខ្លួន ទាំងផ្នែករឹង និងផ្នែកទន់ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ស្ត្រី កុមារ យុវជន មនុស្សចាស់ ជនក្រីក្រ ជនមានពិការភាព ជនជាតិដើមភាគតិច និងជនងាយរងគ្រោះផ្សេងៗទៀត ក្នុងការទទួលបាននូវព័ត៌មាន ចំណេះដឹង និងសេវានានាប្រកបដោយសមធម៌សង្គម បរិយាប័ន្ន និងសេចក្តីថ្លៃថ្នូរ
- អប់រំផ្សព្វផ្សាយបង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋ ជាពិសេសស្ត្រី កុមារ យុវជន មនុស្សចាស់ ជនក្រីក្រ ជនមានពិការភាព ជនជាតិដើមភាគតិច និងជនងាយរងគ្រោះផ្សេងៗទៀត អំពីច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងកិច្ចការសេវាសង្គម និងកិច្ចការអភិវឌ្ឍន៍មូលដ្ឋាន
- សហការជាមួយអង្គភាព ឬអ្នកផ្តល់សេវាសង្គម ភ្នាក់ងារសង្គមកិច្ច អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នានាក្នុងការអនុវត្តសកម្មភាពសេវាសង្គមនានានៅក្នុងឃុំ សង្កាត់របស់ខ្លួន
- កៀរគរធនធាននានាពីស្ថាប័នរដ្ឋ អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ ផ្នែកឯកជន និងសប្បុរសជននានា ដើម្បីគាំទ្រដល់ការអនុវត្តសកម្មភាពសេវាសង្គមនានា ប្រកបដោយសមធម៌សង្គម និងបរិយាប័ន្ន
- សហការជាមួយអង្គភាព ឬភ្នាក់ងារមានសមត្ថកិច្ចនានាក្នុងការទប់ស្កាត់ និងការធ្វើអន្តរាគមន៍ចំពោះករណីអំពើហិង្សា ការបំពានផ្លូវភេទ ការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្មស្ត្រីនិងកុមារ ការចរាចរគ្រឿងញៀន ការប្រើប្រាស់គ្រឿងញៀន និងសកម្មភាពអសកម្មផ្នែកសេវាសង្គមផ្សេងៗទៀត នៅក្នុងឃុំ សង្កាត់
- តាមដាន និងរាយការណ៍ជូនកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់អំពីស្ថានភាពបញ្ហាសង្គម និង



៥

តម្រូវការរបស់ស្ត្រី កុមារ យុវជន មនុស្សចាស់ ជនក្រីក្រ ជនមានពិការភាព ជនជាតិដើមភាគតិច និងជនងាយរងគ្រោះផ្សេងៗទៀត ដើម្បីធានាដល់ការទទួលបាននូវការឆ្លើយតប និងកិច្ចអន្តរាគមន៍ប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា

- រៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តសកម្មភាពសេវាសង្គមទៅតាមការកំណត់ ហើយដាក់ជូនមេឃុំ ចៅសង្កាត់ ដើម្បីដាក់បញ្ចូលទៅក្នុងរបាយការណ៍ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលឃុំ សង្កាត់
- បំពេញការងារផ្សេងៗទៀតតាមការប្រគល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់។

**ប្រការ ៨.-**

សកម្មភាពសេវាសង្គមសំខាន់ៗនៅឃុំ សង្កាត់រួមមាន ៖

***ក). ការងារសុខភាពមាតា ទារក អាហារូបត្ថម្ភ***

- ស្រង់ស្ថិតិស្ត្រីមានផ្ទៃពោះ ទារក និងកុមារស្គមស្គាំង កុមារក្រិសក្រិន ព្រមទាំងតាមដានស្ថានភាពសុខភាពស្ត្រីមានផ្ទៃពោះ ទារក និងកុមារទាំងនោះ
- ចលនា និងជំរុញលើកទឹកចិត្តស្ត្រីមានផ្ទៃពោះ ឱ្យទៅពិនិត្យផ្ទៃពោះជាទៀងទាត់មុនពេលសម្រាល ធ្វើការសម្រាលកូន និងពិនិត្យសុខភាពក្រោយពេលសម្រាលនៅ**មូលដ្ឋានសុខាភិបាលសាធារណៈ**
- ចលនា និងជំរុញលើកទឹកចិត្តឪពុកម្តាយ ឬអ្នកអាណាព្យាបាល យកកូនទៅទទួលថ្នាំបង្ការ (រួមទាំងជីវជាតិបន្ថែម)ឱ្យបានគ្រប់ចំនួន និងតាមពេលវេលាកំណត់
- ផ្តល់ការគាំទ្រថវិកា និងមធ្យោបាយធ្វើដំណើរដល់ស្ត្រីក្រីក្រមានផ្ទៃពោះ ក្នុងការពិនិត្យផ្ទៃពោះមុនពេលសម្រាល ការសម្រាលកូន និងការពិនិត្យសុខភាពក្រោយពេលសម្រាល នៅមូលដ្ឋានសុខាភិបាលសាធារណៈ
- ផ្តល់ការគាំទ្រដល់កុមារស្គមស្គាំង ឬកុមារខ្វះអាហារូបត្ថម្ភ តាមរយៈការរៀបចំកម្មវិធីអាហារូបត្ថម្ភនានា
- គាំទ្រ និងដោះស្រាយបញ្ហានានាក្នុងការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ
- ចូលរួមផ្សព្វផ្សាយសារលិខិតរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជានៅក្នុង **ទិវាជាតិសុខភាពមាតា ទារក និងកុមារ ថ្ងៃទី២១ ខែកុម្ភៈ និងទិវាជាតិអាហារូបត្ថម្ភ ថ្ងៃទី០៦ ខែវិច្ឆិកា**
- ចូលរួមអប់រំផ្សព្វផ្សាយអំពីសារៈសំខាន់នៃការថែទាំសុខភាពមាតានិងទារក ការពិនិត្យផ្ទៃពោះមុនពេលសម្រាល ការពិនិត្យសុខភាពក្រោយពេលសម្រាល ការសម្រាលកូននៅមូលដ្ឋានសុខាភិបាលសាធារណៈ ការចាក់ថ្នាំបង្ការដល់កុមារឱ្យបានគ្រប់ចំនួន ការថែទាំសុខភាពបន្តពូជ និងកម្មវិធីសុខភាពផ្សេងៗទៀត ព្រមទាំងចូលរួមផ្សព្វផ្សាយអំពីជំងឺមានពាក់ព័ន្ធនឹងបញ្ហាជំងឺឆ្លង បញ្ហាជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈផ្សេងៗទៀត៖

## ខ). *ការងារអត្តសញ្ញាណកម្ម*

- ចលនា និងជំរុញលើកទឹកចិត្តឪពុកម្តាយទារក ទៅចុះសៀវភៅអត្រានុកូលដ្ឋានកំណើត និងសំបុត្រកំណើតឱ្យកូនរបស់ខ្លួន **នៅក្នុងអំឡុងពេល៣០ថ្ងៃ** បន្ទាប់ពីកើត
- ចលនា និងជំរុញលើកទឹកចិត្តយុវជន យុវនារី ទៅធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរនៅពេលឈានចូលអាយុ**១៥ឆ្នាំ**
- ចលនា និងជំរុញលើកទឹកចិត្តបុរស ស្ត្រី យុវជន យុវនារី ដែលបានសម្រេចរៀបអាពាហ៍ពិពាហ៍ ទៅចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ និងសំបុត្រអាពាហ៍ពិពាហ៍
- ចលនា និងជំរុញលើកទឹកចិត្តគ្រួសារឬសាច់ញាតិរបស់មរណជនទៅចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព និងសំបុត្រមរណភាព ក្នុងរយៈពេលយ៉ាងយូរ១៥ថ្ងៃ ក្រោយថ្ងៃទទួលមរណភាព
- អប់រំផ្សព្វផ្សាយបង្កើនការយល់ដឹងអំពីកាតព្វកិច្ច និងសារៈសំខាន់នៃការចុះអត្រានុកូលដ្ឋាន និងការធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ។

## គ). *ការងារសិក្សាអប់រំ*

- ចលនា និងជំរុញលើកទឹកចិត្តឪពុកម្តាយ ឬអ្នកអាណាព្យាបាលឱ្យបញ្ជូនកូនដែលមានអាយុ ៣-៥ឆ្នាំចូលរៀនថ្នាក់មត្តេយ្យសិក្សា និងកូនដែលមានអាយុចាប់ពី៦ឆ្នាំ ឬយ៉ាងទាបបំផុតអាយុ ៧០ខែឡើងទៅ ចូលរៀនថ្នាក់ទី១
- ចូលរួមអប់រំផ្សព្វផ្សាយបង្កើនការយល់ដឹងរបស់ឪពុកម្តាយ និងអ្នកអាណាព្យាបាលអំពីសារៈសំខាន់នៃការសិក្សាអប់រំរបស់ក្មេងស្រី ព្រមទាំងជំរុញលើកទឹកចិត្តដល់ក្មេងស្រីឱ្យបន្តការសិក្សានៅកម្រិតឧត្តមសិក្សា
- សម្របសម្រួលការរៀបចំបង្កើត និងដំណើរការមត្តេយ្យសិក្សាសហគមន៍
- តាមដានបញ្ហាអវត្តមានរបស់សិស្ស និងបញ្ហាផ្នែកអប់រំផ្សេងៗទៀត ព្រមទាំងសម្របសម្រួលដោះស្រាយបញ្ហាទាំងនេះ តាមរយៈការជួបពិភាក្សាជាមួយឪពុកម្តាយ ឬអ្នកអាណាព្យាបាលសិស្ស និងលោកគ្រូ អ្នកគ្រូ
- ចូលរួមរៀបចំទិវាជាតិអំណាន **ថ្ងៃទី១១ ខែមីនា**
- ចូលរួមផ្សព្វផ្សាយ និងលើកកម្ពស់ការអប់រំពហុភាសានៅតាមតំបន់ជនជាតិដើមភាគតិច
- ចូលរួមសម្របសម្រួលការអនុវត្តកម្មវិធីនានាពាក់ព័ន្ធនឹងការអភិវឌ្ឍ និងការគាំពារដល់កុមារ ដូចជាកម្មវិធីទារកដ្ឋាន ការអប់រំឪពុកម្តាយ ឬអ្នកអាណាព្យាបាលអំពីរបៀបចិញ្ចឹមកូនតាមបែបវិជ្ជមានជាដើម។

## ឃ). *ការទប់ស្កាត់អំពើហិង្សាទាក់ទងយេនឌ័រ ជាពិសេសអំពើហិង្សាលើស្ត្រី និងកុមារ*

- កំណត់ និងស្រង់ទិន្នន័យជនងាយរងគ្រោះដោយសារអំពើហិង្សា(ផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ និងផ្លូវសេដ្ឋកិច្ច) និងការបំពានខាងផ្លូវភេទ ការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្មស្ត្រីនិងកុមារនៅក្នុងឃុំ សង្កាត់
- ចូលរួមបង្ការ ទប់ស្កាត់ និងធ្វើអន្តរាគមន៍ចំពោះករណីអំពើហិង្សា និងការរំលោភបំពាននានាជាពិសេសទៅលើស្ត្រី និងកុមារ

- សម្របសម្រួលបញ្ជូនជនរងគ្រោះដោយអំពើហិង្សា ឬដោយការរំលោភបំពាននានាទៅទទួលសេវាសង្គ្រោះបន្ទាន់ ឬសេវាសមស្របនានា
- ចូលរួមអនុវត្តវិធានការដោះស្រាយ ឬវិធានការសមស្របនានាដើម្បីជួយដល់ជនរងគ្រោះដោយអំពើហិង្សា ឬដោយការរំលោភបំពាន រហូតជនរងគ្រោះទាំងនេះ អាចរស់នៅបានប្រកបដោយសុវត្ថិភាព និងសុខដុមមនា
- តាមដាន កត់ត្រា និងរាយការណ៍អំពីករណីអំពើហិង្សា និងការរំលោភបំពាននានា។

### ង). *ការងារកិច្ចការពារកុមារ*

- កំណត់ និងស្រង់ទិន្នន័យ**កុមាររងគ្រោះ និងងាយរងគ្រោះ** នៅក្នុងឃុំ សង្កាត់
- ចូលរួមបង្ការ ទប់ស្កាត់ និងធ្វើអន្តរាគមន៍ចំពោះករណីអំពើហិង្សា ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការរំលោភបំពាននានាលើកុមារ
- សម្របសម្រួលបញ្ជូនកុមាររងគ្រោះដោយអំពើហិង្សា និងការរំលោភបំពាននានាទៅទទួលសេវាសមស្រប និងសេវាឯកទេស( ចិត្តសង្គម សុខភាព ផ្លូវច្បាប់ )
- ចូលរួមផ្សព្វផ្សាយសារលិខិតរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជានៅក្នុង**ទិវាកុមារអន្តរជាតិ ថ្ងៃទី០១ ខែមិថុនា**
- ចូលរួមអនុវត្តវិធានការសមស្របនានា ដោយផ្អែកលើគោលការណ៍ឧត្តមប្រយោជន៍កុមារ ដើម្បីអភិវឌ្ឍ និងជួយដល់កុមាររងគ្រោះ រហូតដល់កុមាររងគ្រោះទាំងនេះ អាចរស់នៅបានប្រកបដោយសុវត្ថិភាព ព្រមទាំងទទួលបានការអប់រំមូលដ្ឋាន៩ឆ្នាំយ៉ាងតិច និងកម្មវិធីអភិវឌ្ឍន៍សមត្ថភាពជំនាញនានាសម្រាប់ការបំពេញការងារ។

### ច). *ការងារទឹកស្អាត និងអនាម័យ*

- ចលនា និងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យប្រើប្រាស់ ឬបរិភោគទឹកដែលមានសុវត្ថិភាព
- ចលនា និងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យប្រើប្រាស់បង្គន់អនាម័យ លាងដៃនឹងសាប៊ូ និងប្រតិបត្តិជាប្រចាំនូវអនាម័យសំខាន់ៗផ្សេងទៀត
- ផ្តល់ការគាំទ្រដល់គ្រួសារដែលពុំមានលទ្ធភាពក្នុងការប្រើប្រាស់ទឹកដែលមានសុវត្ថិភាព និងឬបង្គន់អនាម័យ
- ចូលរួមរៀបចំទិវាអនាម័យសំខាន់ៗ ដូចជា**ទិវាទឹកពិភពលោក ថ្ងៃទី២២ ខែមីនា ទិវាពិភពលោកលាងដៃស្អាត ថ្ងៃទី១៥ ខែតុលា** និង**ទិវាជាតិលើកកម្ពស់អនាម័យជនបទ ថ្ងៃទី១៣ ខែវិច្ឆិកា** ជាដើម។

### ឆ). *ការងារពិការភាព*

- ចលនា និងជំរុញលើកទឹកចិត្តដល់ជនមានពិការភាព និងគ្រួសារ ឱ្យចូលរួមក្នុងដំណើរការកំណត់អត្តសញ្ញាណកម្មជនមានពិការភាព
- ស្រង់ស្ថិតិគ្រួសារដែលមានសមាជិកជាជនមានពិការភាព
- កំណត់បញ្ហា តម្រូវការ និងដំណោះស្រាយចាំបាច់នានារបស់ជនមានពិការភាព
- ចូលរួមអនុវត្តវិធានការសមស្របនានាដើម្បីឱ្យជនមានពិការភាពទទួលបានព័ត៌មាន ចំណេះដឹង

និងសេវានានាប្រកបដោយសមធម៌សង្គម បរិយាប័ន្ន និងមានជីវភាពរស់នៅប្រកបដោយសុវត្ថិភាពនិងសេចក្តីថ្លៃថ្នូរ

- ចូលរួមរៀបចំទិវាជនមានពិការភាពកម្ពុជា ថ្ងៃទី០៣ ខែធ្នូ។

*ជ). ការងារជនក្រីក្រ និងមនុស្សចាស់*

- ស្រង់ស្ថិតិគ្រួសារក្រីក្រ ឬចូលរួមកិច្ចដំណើរការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ព្រមទាំងស្ថិតិមនុស្សចាស់ មនុស្សចាស់ក្រីក្រ
- កំណត់បញ្ហា តម្រូវការ និងដំណោះស្រាយនានារបស់ជនក្រីក្រ ជនចាស់ជរា និងមនុស្សចាស់ ចូលរួមអនុវត្តវិធានការសមស្របនានាដើម្បីជួយដល់ជនក្រីក្រ ជនចាស់ជរា និងមនុស្សចាស់ក្នុងការទទួលបាននូវជីវភាពរស់នៅប្រកបដោយសុវត្ថិភាពនិងសេចក្តីថ្លៃថ្នូរ
- ចូលរួមសម្របសម្រួល និងគាំទ្រការរៀបចំបង្កើត និងដំណើរការរបស់សមាគមមនុស្សចាស់នៅតាមសហគមន៍
- ចូលរួមរៀបចំទិវាមនុស្សចាស់កម្ពុជា ថ្ងៃទី០១ ខែតុលា។

*ឈ). ការបង្ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន (រួមទាំងគ្រឿងស្រវឹង)*

- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ជាពិសេសយុវជនអំពីផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន និងគ្រឿងស្រវឹង
- ចូលរួមកំណត់មុខសញ្ញាអ្នកចរាចរ និងឬអ្នកប្រើប្រាស់គ្រឿងញៀន
- ចូលរួមអនុវត្តវិធានការសមស្របនានា ដើម្បីបង្ការ និងទប់ស្កាត់ការចរាចរ និងការប្រើប្រាស់គ្រឿងញៀន ព្រមទាំងការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន។

*ញ). ការលើកកម្ពស់សមភាពយេនឌ័រ*

- ចលនា និងជំរុញលើកទឹកចិត្តស្ត្រីឱ្យចូលរួមនៅក្នុងដំណើរការធ្វើសេចក្តីសម្រេច និងអនុវត្តសេចក្តីសម្រេចរបស់រដ្ឋបាលឃុំ សង្កាត់
- ចលនា និងជំរុញលើកទឹកចិត្តស្ត្រីឱ្យចូលរួមសកម្មភាពនយោបាយ និងអភិវឌ្ឍន៍សេដ្ឋកិច្ច ដើម្បីលើកកម្ពស់ឋានៈស្ត្រីនៅក្នុងគ្រួសារ និងសង្គមជាតិ
- ចូលរួមអនុវត្តវិធានការសមស្របនានាដើម្បីផ្តល់ភាពអង់អាចដល់ស្ត្រី និងលើកកម្ពស់សមធម៌សង្គម និងបរិយាប័ន្ន
- ចូលរួមផ្សព្វផ្សាយអំពីការផ្លាស់ប្តូរឥរិយាបថ និងផ្នត់គំនិតអវិជ្ជមានដែលរារាំងដល់ស្ត្រី និងក្មេងស្រីក្នុងការចូលរួមការងារសង្គម និងសហគមន៍
- ចូលរួមផ្សព្វផ្សាយសារលិខិតរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជានៅក្នុងទិវានារីអន្តរជាតិ ថ្ងៃទី០៨ ខែមីនា។

*ដ). ការងារសេវាសង្គមផ្សេងៗទៀត*

- សម្របសម្រួល និងអនុវត្តសកម្មភាពសេវាសង្គមផ្សេងៗទៀត ដែលបានផ្ទេរឱ្យរដ្ឋបាលឃុំ សង្កាត់។

## ជំពូកទី៣
## របៀបរបបការងារ និងទំនាក់ទំនង
## របស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់

**ប្រការ ៩.-**

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ និងប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់សាមីក្នុងការបំពេញការងាររបស់ខ្លួន។

អនុប្រធាន និងសមាជិកគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះប្រធានគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់របស់ខ្លួន។

**ប្រការ ១០.-**

ក្នុងករណីប្រធានគណៈកម្មាធិការអវត្តមាន ឬពុំអាចបំពេញការងារបាន ប្រធានគណៈកម្មាធិការត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរជូនអនុប្រធានគណៈកម្មាធិការ ឱ្យទទួលជាប្រធានគណៈកម្មាធិការស្តីទី ដើម្បីដឹកនាំ និងចាត់ចែងការងាររបស់គណៈកម្មាធិការ។ អនុប្រធានគណៈកម្មាធិការដែលទទួលបាននូវការផ្ទេរសិទ្ធិជាប្រធានគណៈកម្មាធិការស្តីទី ពុំមានសិទ្ធិក្នុងការផ្ទេរសិទ្ធិបន្តទៅឱ្យសមាជិកគណៈកម្មាធិការណាមួយក្នុងគណៈកម្មាធិការរបស់ខ្លួន ធ្វើជាប្រធានគណៈកម្មាធិការស្តីទីបានឡើយ។

**ក្នុងករណីប្រធានគណៈកម្មាធិការអវត្តមានដោយពុំបានផ្ទេរសិទ្ធិ ត្រូវអនុវត្តដូចខាងក្រោម ៖**

- **បើអនុប្រធានគណៈកម្មាធិការមានវត្តមាន ៖** អនុប្រធានគណៈកម្មាធិការ ត្រូវបានទទួលសិទ្ធិដោយស្វ័យប្រវត្តិ ជាប្រធានគណៈកម្មាធិការស្តីទី។
- **បើអនុប្រធានគណៈកម្មាធិការអវត្តមាន ៖**
  - មេឃុំ ចៅសង្កាត់ស្តីទីត្រូវបានទទួលសិទ្ធិដោយស្វ័យប្រវត្តិ ជាប្រធានគណៈកម្មាធិការស្តីទី ករណីមេឃុំ ចៅសង្កាត់ ជាប្រធានគណៈកម្មាធិការ។
  - មេឃុំ ចៅសង្កាត់ ឬមេឃុំ ចៅសង្កាត់ស្តីទីត្រូវបានទទួលសិទ្ធិដោយស្វ័យប្រវត្តិ ជាប្រធានគណៈកម្មាធិការស្តីទី ករណីជំទប់ទី២ ចៅសង្កាត់រងទី២ ជាប្រធានគណៈកម្មាធិការ។

**ក្នុងករណីប្រធានគណៈកម្មាធិការស្តីទីអវត្តមាន ត្រូវអនុវត្តដូចខាងក្រោម ៖**

- មេឃុំ ចៅសង្កាត់ស្តីទីត្រូវបានទទួលសិទ្ធិដោយស្វ័យប្រវត្តិ ជាប្រធានគណៈកម្មាធិការស្តីទី ករណីមេឃុំ ចៅសង្កាត់ ជាប្រធានគណៈកម្មាធិការ។
- មេឃុំ ចៅសង្កាត់ ឬមេឃុំ ចៅសង្កាត់ស្តីទីត្រូវបានទទួលសិទ្ធិដោយស្វ័យប្រវត្តិ ជាប្រធានគណៈ-កម្មាធិការស្តីទី ករណីជំទប់ទី២ ចៅសង្កាត់រងទី២ ជាប្រធានគណៈកម្មាធិការ។

**ប្រការ ១១.-**

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់មានសិទ្ធិប្រើប្រាស់ត្រារបស់រដ្ឋបាលឃុំ សង្កាត់ ក្នុងការបោះត្រាលើឯកសារនានារបស់គណៈកម្មាធិការ ដែលចុះហត្ថលេខាដោយប្រធានគណៈកម្មាធិការ ឬប្រធានគណៈកម្មាធិការស្តីទី ដោយប្រើរូបមន្តនៃមុខតំណែងហត្ថលេខាដូចខាងក្រោម ៖

- ករណីប្រធានគណៈកម្មាធិការមានវត្តមាន៖

**៦. គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់**
**ប្រធាន**

- ករណីប្រធានគណៈកម្មាធិការអវត្តមាន៖

**៦. គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់**
**ប្រធានស្តីទី**

**ប្រការ ១២.-**

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់មានរបបប្រជុំសាមញ្ញជាប្រចាំខែ និងប្រជុំវិសាមញ្ញតាមការចាំបាច់។

កិច្ចប្រជុំគណៈកម្មាធិការអាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកលើសពីពាក់កណ្តាលនៃសមាជិកគណៈកម្មាធិការទាំងមូល។

ប្រធានគណៈកម្មាធិការ ជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មាធិការ។ ក្នុងករណីប្រធានអវត្តមាន ប្រធានស្តីទីជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ។

សេចក្តីសម្រេចរបស់អង្គប្រជុំគណៈកម្មាធិការ អាចយកជាការបាន លុះត្រាតែមានសំឡេងអនុម័តលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មាធិការទាំងមូល។ ក្នុងករណីសំឡេងអនុម័តមានចំនួនស្មើគ្នា សំឡេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព។

ប្រធានគណៈកម្មាធិការ អាចអញ្ជើញតំណាងអង្គការមិនមែនរដ្ឋាភិបាលដែលបំពេញការងារពាក់ព័ន្ធនឹងសេវាសង្គម អ្នកផ្តល់សេវាសង្គម និងអ្នកពាក់ព័ន្ធនានាតាមការចាំបាច់ ដើម្បីចូលរួមក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការ។

គ្រប់កិច្ចប្រជុំរបស់គណៈកម្មាធិការ ត្រូវមានកំណត់ហេតុ ដែលរៀបចំដោយលេខាធិការរបស់គណៈកម្មាធិការ និងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។ បន្ទាប់ពីកិច្ចប្រជុំនីមួយៗ លេខាធិការគណៈកម្មាធិការ ត្រូវរៀបចំកំណត់ហេតុប្រជុំ ហើយដាក់ជូនអធិបតីអង្គប្រជុំពិនិត្យ និងចុះហត្ថលេខាយ៉ាងយូរ ០៣ថ្ងៃក្រោយកិច្ចប្រជុំ។

គណៈកម្មាធិការត្រូវរៀបចំ និងអនុម័តប្រតិទិនប្រជុំប្រចាំខែរបស់ខ្លួនសម្រាប់ឆ្នាំនីមួយៗ ហើយចែកជូនសមាជិកគណៈកម្មាធិការគ្រប់រូប និងអ្នកពាក់ព័ន្ធនានា ដើម្បីត្រៀមពេលវេលា និងរបាយការណ៍សម្រាប់ចូលរួម និងរាយការណ៍ជូនកិច្ចប្រជុំរបស់គណៈកម្មាធិការ។

កិច្ចប្រជុំប្រចាំខែរបស់គណៈកម្មាធិការ មានរបៀបវារៈដូចខាងក្រោម៖

- ផ្សព្វផ្សាយអំពីសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងរបស់រាជរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងគណៈកម្មាធិការ
- ពិនិត្យ និងអនុម័តរបាយការណ៍ប្រចាំខែស្តីពីការអនុវត្តការងារសេវាសង្គម
- ពិនិត្យ និងអនុម័តរបាយការណ៍ប្រចាំខែស្តីពីការអនុវត្តថវិកាសេវាសង្គម
- ពិនិត្យ ពិភាក្សា និងដោះស្រាយបញ្ហាប្រឈមនានាដែលពាក់ព័ន្ធនឹងសេវាសង្គម
- ពិភាក្សា និងអនុម័តផែនការការងារសម្រាប់ខែបន្ទាប់។

កិច្ចប្រជុំប្រចាំខែធ្នូនៃឆ្នាំនីមួយៗ គឺជាកិច្ចប្រជុំប្រចាំឆ្នាំ ដែលមានរបៀបវារៈដូចខាងក្រោម ៖

- ផ្សព្វផ្សាយអំពីសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងរបស់រាជរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងគណៈកម្មាធិការ
- ពិនិត្យ និងអនុម័តរបាយការណ៍ប្រចាំខែធ្នូ និងប្រចាំឆ្នាំស្តីពីការអនុវត្តការងារសេវាសង្គម
- ពិនិត្យ និងអនុម័តរបាយការណ៍ប្រចាំខែធ្នូ និងប្រចាំឆ្នាំស្តីពីការអនុវត្តថវិកាសេវាសង្គម
- ពិនិត្យ ពិភាក្សា និងដោះស្រាយបញ្ហាប្រឈមនានាដែលពាក់ព័ន្ធនឹងសេវាសង្គម
- ពិភាក្សា និងអនុម័តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់អនុវត្តសកម្មភាពសេវាសង្គមសម្រាប់ឆ្នាំបន្ទាប់
- ពិភាក្សា និងអនុម័តផែនការការងារសម្រាប់ខែមករានៃឆ្នាំបន្ទាប់។

**ប្រការ ១៣.-**

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់អនុវត្តសកម្មភាពសេវាសង្គម ហើយដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យនិងអនុម័ត ដើម្បីដាក់បញ្ចូលទៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់។

ផ្អែកតាមផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំនេះ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវរៀបចំផែនការសកម្មភាព និងថវិកាប្រចាំត្រីមាស និងប្រចាំខែសម្រាប់ជាមូលដ្ឋាននៃការបំពេញការងាររបស់ខ្លួន។

**ប្រការ ១៤.-**

សមាជិកគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវផ្តល់របាយការណ៍ប្រចាំខែស្តីពីលទ្ធផលនៃការអនុវត្តការងារក្នុងវិស័យដែលខ្លួនទទួលខុសត្រូវ មកប្រធានគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ដើម្បីបូកសរុប និងរៀបចំរបាយការណ៍ប្រចាំខែរបស់គណៈកម្មាធិការ។

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវរៀបចំរបាយការណ៍ប្រចាំខែ និងប្រចាំឆ្នាំស្តីពីការអនុវត្តការងាររបស់ខ្លួន រួមទាំងរបាយការណ៍ថវិកាសេវាសង្គម ហើយដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យ និងអនុម័ត ដើម្បីដាក់បញ្ចូលទៅក្នុងរបាយការណ៍ប្រចាំខែ និងប្រចាំឆ្នាំស្តីពីការអនុវត្តការងាររបស់រដ្ឋបាលឃុំ សង្កាត់។

**ប្រការ ១៥.-**

តាមរយៈរដ្ឋបាលឃុំ សង្កាត់សាមី គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ធ្វើទំនាក់ទំនងជាមួយអង្គភាពនានា ដូចខាងក្រោម ៖

- ចូលរួមកិច្ចប្រជុំរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទៅតាមការអញ្ជើញ
- ផ្តល់ព័ត៌មានអំពីបញ្ហា និងតម្រូវការរបស់ស្ត្រី កុមារ យុវជន មនុស្សចាស់ ជនក្រីក្រ ជនមានពិការភាព ជនជាតិដើមភាគតិច និងជនងាយរងគ្រោះផ្សេងៗទៀតនៅក្នុងឃុំ សង្កាត់ ដល់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- លើកសំណើអំពីបញ្ហាសេវាសង្គមនានាដែលរដ្ឋបាលឃុំ សង្កាត់របស់ខ្លួនពុំអាចដោះស្រាយបាន



៤

ជូនទៅគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីចាត់វិធានការដោះស្រាយ ឬអន្តរាគមន៍ទាន់ពេលវេលា

- សហការ និងចូលរួមជាមួយគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មន្ទីរ អង្គភាពជំនាញ អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នានាក្នុងការអនុវត្តសកម្មភាពសេវាសង្គមនានានៅក្នុងដែនដីនៃរដ្ឋបាលឃុំ សង្កាត់របស់ខ្លួន
- ទទួលយកកម្មវិធីអភិវឌ្ឍន៍សមត្ថភាពនានាពីរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មន្ទីរ អង្គភាពជំនាញ អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នានា ដើម្បីកសាងសមត្ថភាពសមាជិករបស់ខ្លួន
- ស្នើសុំការគាំទ្រថវិកា និងឬបច្ចេកទេសពីរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មន្ទីរ អង្គភាពជំនាញ អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នានា ក្នុងការអនុវត្តសកម្មភាពសេវាសង្គមនានានៅក្នុងដែនដីនៃរដ្ឋបាលឃុំ សង្កាត់របស់ខ្លួន ដើម្បីលើកកម្ពស់ស្ថានភាព និងជីវភាពរស់នៅរបស់ស្ត្រី កុមារ យុវជន មនុស្សចាស់ ជនក្រីក្រ ជនមានពិការភាព ជនជាតិដើមភាគតិច និងជនងាយរងគ្រោះផ្សេងៗទៀត។

## ជំពូកទី៤
## ថវិកាប្រតិបត្តិការរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់

**ប្រការ ១៦.-**

រដ្ឋបាលឃុំ សង្កាត់នីមួយៗត្រូវគ្រោងថវិកាផ្នែករដ្ឋបាលទូទៅនៃមូលនិធិឃុំ សង្កាត់សម្រាប់ចំណាយប្រតិបត្តិការរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ នៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួន។

## ជំពូកទី៥
## ការជ្រើសរើស និងការតែងតាំងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់

**ប្រការ ១៧.-**

រដ្ឋបាលឃុំ សង្កាត់នៃអាណត្តិក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ត្រូវតែងតាំងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រីមួយរូប ឱ្យទទួលបន្ទុកកិច្ចការនារីនិងកុមារ និងកិច្ចការសេវាសង្គមនៅឃុំ សង្កាត់របស់ខ្លួន ហៅថា **អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់** សរសេរជាអក្សរកាត់ថា **អ.ក.ន.ក.**។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងប្រកាសនេះ សំដៅដល់ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល ដែលក្នុងនោះរួមមានមេឃុំ ចៅសង្កាត់ ជំទប់ទី១ ចៅសង្កាត់រងទី១ ជំទប់ទី២ ចៅសង្កាត់រងទី២ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ផ្សេងៗទៀត។

**ប្រការ ១៨.-**

ការជ្រើសរើសអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ត្រូវអនុវត្តដូចខាងក្រោម៖

- **ក្នុងករណីក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិកតែមួយរូបជាស្ត្រី ហើយមិនត្រូវបានតែងតាំងជាមេឃុំ ចៅសង្កាត់ ឬជាជំទប់ទី១ ចៅសង្កាត់រងទី១** សមាជិកក្រុមប្រឹក្សាជាស្ត្រីមួយរូបនោះ ត្រូវបានជ្រើសរើសជាអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់។

- **ក្នុងករណីក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិកជាស្ត្រីលើសពីមួយរូប ហើយមិនត្រូវបានតែងតាំងជាមេឃុំ ចៅសង្កាត់ ឬជាជំទប់ទី១ ចៅសង្កាត់រងទី១ ៖** ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកោះប្រជុំក្រុមប្រឹក្សារបស់ខ្លួន ដើម្បីសម្រេចជ្រើសរើសសមាជិកក្រុមប្រឹក្សាជាស្ត្រីមួយរូប ជាអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់។
- **ក្នុងករណីក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិកតែមួយរូបជាស្ត្រី ហើយត្រូវបានតែងតាំងជាមេឃុំ ចៅសង្កាត់ ឬជាជំទប់ទី១ ចៅសង្កាត់រងទី១ ឬក្នុងករណីក្រុមប្រឹក្សាឃុំ សង្កាត់ពុំមានសមាជិកជាស្ត្រី ៖** មេឃុំ ចៅសង្កាត់ត្រូវសម្របសម្រួលជ្រើសរើសថ្នាក់ដឹកនាំភូមិ(មេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិ)ជាស្ត្រីមួយរូប ដែលមានសមត្ថភាព និងបទពិសោធន៍កិច្ចការសេវាសង្គម សម្រាប់ធ្វើជាអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ ហើយដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាពិនិត្យ និងអនុម័ត។

បន្ទាប់ពីជ្រើសរើសបាន មេឃុំ ចៅសង្កាត់ត្រូវចេញសេចក្តីសម្រេចស្តីពីការតែងតាំងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់(**ទម្រង់ទី២**)។

**ប្រការ ១៩.-**

អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវបានផ្តល់សិទ្ធិឱ្យចូលរួមកិច្ចពិភាក្សា ឬកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ លើកលែងតែសាមីខ្លួនជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។

អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវបានផ្តល់សិទ្ធិឱ្យចូលរួមកិច្ចពិភាក្សា ឬកិច្ចប្រជុំរបស់គណៈកម្មាធិការនានារបស់រដ្ឋបាលឃុំ សង្កាត់ ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ លើកលែងតែសាមីខ្លួនជាសមាជិកនៃគណៈកម្មាធិការនោះ។

**ប្រការ ២០.-**

អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់មានតួនាទីជួយរដ្ឋបាលឃុំ សង្កាត់ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់លើកិច្ចការសេវាសង្គមទាំងអស់នៅក្នុងឃុំ សង្កាត់។

អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់មានភារកិច្ចដូចខាងក្រោម ៖

- សម្របសម្រួលការងារប្រចាំថ្ងៃ និងការរៀបចំកិច្ចប្រជុំរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់
- ពិនិត្យ និងផ្តល់យោបល់ទៅលើសេចក្តីព្រាងប្រតិទិនប្រជុំសាមញ្ញ សេចក្តីព្រាងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់អនុវត្តសកម្មភាពសេវាសង្គម សេចក្តីព្រាងរបាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តសេវាសង្គម សេចក្តីព្រាងរបាយការណ៍ស្តីពីការអនុវត្តថវិកាសេវាសង្គម និងសេចក្តីព្រាងឯកសារពាក់ព័ន្ធនឹងបញ្ហា តម្រូវការ និងដំណោះស្រាយផ្នែកសេវាសង្គមសម្រាប់ដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់
- សម្របសម្រួលការអនុវត្តសកម្មភាពសេវាសង្គមនានានៅក្នុងឃុំ សង្កាត់ ព្រមទាំងការតាមដានត្រួតពិនិត្យ និងការវាយតម្លៃទៅលើការអនុវត្តសកម្មភាពសេវាសង្គមនានានៅក្នុងឃុំ សង្កាត់
- ចូលរួមដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ការរៀបចំ

គម្រោងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់ និងការរៀបចំកម្មវិធីផ្សេងៗទៀតរបស់ឃុំ សង្កាត់ពាក់ព័ន្ធនឹងការងារសេវាសង្គម

- សម្របសម្រួលការអប់រំផ្សព្វផ្សាយអំពីកិច្ចការសេវាសង្គម និងចលនាប្រជាពលរដ្ឋឱ្យចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចនានាពាក់ព័ន្ធនឹងការងារសេវាសង្គម ទទួលយកសេវាសង្គមនានា និងរួមចំណែកក្នុងការបង្ការ ការទប់ស្កាត់ និងការដោះស្រាយបញ្ហាសង្គមនានានៅក្នុងឃុំ សង្កាត់ ប្រកបដោយសមធម៌សង្គម និងបរិយាប័ន្ន
- បំពេញការងារផ្សេងៗទៀតតាមការប្រគល់របស់មេឃុំ ចៅសង្កាត់ និងប្រធានគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់។

## ជំពូកទី៦
## ការជ្រើសរើស និងការតែងតាំងជំនួយការសេវាសង្គមឃុំ សង្កាត់

**ប្រការ ២១.-**

ផ្អែកលើក្របខ័ណ្ឌធនធាន និងតម្រូវការជាចាំបាច់ក្នុងការជួយដល់រដ្ឋបាលរបស់ខ្លួនលើការងារសេវាសង្គម រដ្ឋបាលឃុំ សង្កាត់នៃអាណត្តិក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ត្រូវពិចារណាសម្រេចជ្រើសរើសបុគ្គលិកក្រៅក្របខ័ណ្ឌរដ្ឋមួយរូប ជា**ជំនួយការសេវាសង្គមឃុំ សង្កាត់**។

ប្រាក់កម្រៃប្រចាំខែសម្រាប់ជំនួយការសេវាសង្គមឃុំ សង្កាត់ មានចំនួនស្មើនឹងប្រាក់កម្រៃប្រចាំខែរបស់មន្ត្រីជាប់កិច្ចសន្យា ដែលកំណត់ដោយរាជរដ្ឋាភិបាល។

ការជ្រើសរើសជំនួយការសេវាសង្គមឃុំ សង្កាត់ ត្រូវអនុវត្តតាមនីតិវិធីនៃការជ្រើសរើសបុគ្គលិកក្រៅក្របខ័ណ្ឌរដ្ឋរបស់រដ្ឋបាលឃុំ សង្កាត់ជាធរមាន។

បន្ទាប់ពីជ្រើសរើសបាន មេឃុំ ចៅសង្កាត់ត្រូវចេញសេចក្តីសម្រេចស្តីពីការតែងតាំងជំនួយការសេវាសង្គមឃុំ សង្កាត់(**ទម្រង់ទី៣**)។

**ប្រការ ២២.-**

ជំនួយការសេវាសង្គមឃុំ សង្កាត់មានតួនាទីជួយរដ្ឋបាលឃុំ សង្កាត់ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និងស្មៀនឃុំ សង្កាត់លើកិច្ចការសេវាសង្គមទាំងអស់នៅក្នុងឃុំ សង្កាត់។

ជំនួយការសេវាសង្គមឃុំ សង្កាត់មានភារកិច្ចដូចខាងក្រោម ៖

- សម្របសម្រួលកិច្ចការរដ្ឋបាលរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់
- រៀបចំសេចក្តីព្រាងប្រតិទិនប្រជុំសាមញ្ញរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់
- រៀបចំកិច្ចប្រជុំរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ដែលក្នុងនោះរួមមានការរៀបចំ ៖
  - របៀបវារៈ
  - លិខិតអញ្ជើញ
  - កន្លែងប្រជុំ
  - ឯកសារនានាសម្រាប់ពិភាក្សានៅក្នុងកិច្ចប្រជុំ
  - កំណត់ហេតុប្រជុំ។



៨

- រៀបចំសេចក្តីព្រាងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់អនុវត្តសកម្មភាពសេវាសង្គម
- ប្រមូលរបាយការណ៍ប្រចាំខែស្តីពីលទ្ធផលនៃការអនុវត្តការងារសេវាសង្គមពីសមាជិកគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់
- រៀបចំសេចក្តីព្រាងរបាយការណ៍ស្តីពីការអនុវត្តសកម្មភាពសេវាសង្គម និងរបាយការណ៍ស្តីពីការអនុវត្តថវិកាសេវាសង្គម
- ចូលរួមជាមួយសមាជិកនានានៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ក្នុងការចលនាប្រជាពលរដ្ឋ ឱ្យចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចនានារបស់ឃុំ សង្កាត់ ដែលពាក់ព័ន្ធនឹងការងារសេវាសង្គម
- រៀបចំសេចក្តីព្រាងឯកសារពាក់ព័ន្ធនឹងបញ្ហា តម្រូវការ និងដំណោះស្រាយផ្នែកសេវាសង្គម សម្រាប់ដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់
- ចូលរួមដំណើរការកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់ និងការរៀបចំកម្មវិធីផ្សេងៗទៀតរបស់ឃុំ សង្កាត់ពាក់ព័ន្ធនឹងការងារសេវាសង្គម
- ចូលរួមសម្របសម្រួលក្នុងការអនុវត្តសកម្មភាពសេវាសង្គមនានានៅក្នុងឃុំ សង្កាត់ ព្រមទាំងការតាមដានត្រួតពិនិត្យ និងការវាយតម្លៃទៅលើការអនុវត្តសកម្មភាពសេវាសង្គមនានានៅក្នុងឃុំ សង្កាត់
- ចូលរួមអប់រំផ្សព្វផ្សាយអំពីកិច្ចការសេវាសង្គម និងចលនាប្រជាពលរដ្ឋ ឱ្យទៅទទួលយកសេវាសង្គមនានា និងរួមចំណែកក្នុងការបង្ការ ការទប់ស្កាត់ និងការដោះស្រាយបញ្ហាសង្គមនានា នៅក្នុងឃុំ សង្កាត់ ប្រកបដោយសមធម៌សង្គម និងបរិយាប័ន្ន
- ចូលរួមជាមួយអង្គភាពមានសមត្ថកិច្ចនានាក្នុងការទប់ស្កាត់ និងការធ្វើអន្តរាគមន៍ចំពោះករណីអំពើហិង្សា ការបំពានផ្លូវភេទ ការជួញដូរផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្មស្ត្រីនិងកុមារ និងសកម្មភាពអសកម្មផ្នែកសេវាសង្គមផ្សេងៗទៀតនៅក្នុងឃុំ សង្កាត់
- ទុកដាក់ឯកសារនានារបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់
- បំពេញការងារផ្សេងៗទៀតតាមការប្រគល់របស់មេឃុំ ចៅសង្កាត់ និងប្រធានគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់។

## ជំពូកទី៧
## អន្តរប្បញ្ញត្តិ

**ប្រការ ២៣.-**

នៅក្នុងអំឡុងពេលមិនទាន់បានរៀបចំបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់តាមស្មារតីនៃប្រកាសនេះ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ដែលបានបង្កើតឡើងតាមស្មារតីនៃសេចក្តីណែនាំលេខ ០៨២ សណន/គ.ជ.វ.វ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៧ របស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ស្តីពីការរៀបចំ និងការបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារនៅគ្រប់ឃុំ សង្កាត់ទូទាំងប្រទេស នៅតែបន្តអនុវត្តការងាររបស់ខ្លួន។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**ប្រការ ២៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ២៥.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គាធិការនៃអគ្គាធិការដ្ឋាន ក្រសួងមហាផ្ទៃ ក្រុមប្រឹក្សារាជធានី គណៈអភិបាលរាជធានី ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក ក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ មេឃុំ ចៅសង្កាត់ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៤កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**<u>កន្លែងទទួល ៖</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- លេខាធិការដ្ឋាន គ.ជ.អ.ប
- ដូចប្រការ២៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

*ទម្រង់ទី១ ៖ សេចក្ដីសម្រេចស្ដីពីការបង្កើតគណៈកម្មាធិការ*

(ក្បាលលិខិត)

# សេចក្ដីសម្រេច
# ស្ដីពី
# ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុក
# កិច្ចការនារី និងកុមារឃុំ ឬសង្កាត់...................

**មេឃុំ ឬចៅសង្កាត់....................**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្ដីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញប្រកាសលេខ............ ចុះថ្ងៃទី..... ខែ........ ឆ្នាំ២០... របស់ក្រសួងមហាផ្ទៃ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់
- បានទទួលការអនុម័តនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ ឬសង្កាត់........... នាថ្ងៃទី..... ខែ.......... ឆ្នាំ២០...

# សម្រេច

**ប្រការ ១.-**

បង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ឬសង្កាត់.............................. ដែលមានសមាសភាព ដូចខាងក្រោម៖

| | | |
|---|---|---|
| ១. លោក លោកស្រី........................... | មេឃុំ | ជាប្រធាន |
| ២. លោក លោកស្រី........................... | ជំទប់ទី២ | ជាអនុប្រធាន |
| ៣. លោក លោកស្រី.................. | អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ | ជាសមាជិកអចិន្ត្រៃយ៍ |
| ៤. លោក លោកស្រី........................... | ស្មៀនឃុំ | ជាសមាជិក |
| ៥. លោក លោកស្រី........................... | នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ | ជាសមាជិក |
| ៦. លោក លោកស្រី........................... | នាយក/នាយិកាសាលាបឋមសិក្សា | ជាសមាជិក |
| ៧. លោក លោកស្រី........................... | នាយក/នាយិកាសាលាមត្តេយ្យសិក្សា | ជាសមាជិក |
| ៨. លោក លោកស្រី........................... | ប្រធានមណ្ឌលសុខភាព......... | ជាសមាជិក |
| ៩. លោក លោកស្រី......................... | មេភូមិ................................ | ជាសមាជិក |
| ១០. លោក លោកស្រី......................... | មេភូមិ................................. | ជាសមាជិក |
| ១១. លោក លោកស្រី......................... | មេភូមិ................................. | ជាសមាជិក |
| ១២. លោក លោកស្រី............... | តំណាងក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនឃុំ | ជាសមាជិក |
| ១៣. លោក លោកស្រី............... | តំណាងសមាគមមនុស្សចាស់ | ជាសមាជិក |
| ១៤. លោក លោកស្រី............... | តំណាងជនមានពិការភាព | ជាសមាជិក |
| ១៥. លោក លោកស្រី......................... | ជំនួយការសេវាសង្គមឃុំ | ជាលេខាធិការ |

**ប្រការ ២.-**

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់មានតួនាទីផ្តល់យោបល់ និងជួយរដ្ឋបាលឃុំ សង្កាត់ក្នុងការសម្របសម្រួល និងការអនុវត្តសកម្មភាពសេវាសង្គមទាំងអស់នៅក្នុងឃុំ សង្កាត់របស់ខ្លួន ដើម្បីធានាថា ស្ត្រី កុមារ យុវជន មនុស្សចាស់ ជនក្រីក្រ ជនមានពិការភាព ជនជាតិដើមភាគតិច និងជនងាយរងគ្រោះផ្សេងៗទៀត ទទួលបានព័ត៌មាន ចំណេះដឹង និងសេវានានាប្រកបដោយសមធម៌សង្គម និងបរិយាប័ន្ន ព្រមទាំងមានជីវភាពរស់នៅប្រកបដោយសុវត្ថិភាព សុខដុមរមនា និងសេចក្តីថ្លៃថ្នូរ។

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់មានភារកិច្ចដូចខាងក្រោម៖

- ........................................................................................................................
- ........................................................................................................................
- ........................................................................................................................
- ........................................................................................................................
- ........................................................................................................................
- ........................................................................................................................
- ........................................................................................................................
- ........................................................................................................................
- ........................................................................................................................
- ........................................................................................................................

**ប្រការ ៣.-**

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវសម្របសម្រួល និងអនុវត្តសកម្មភាពសេវាសង្គមនានា ដូចមានចែងក្នុងប្រការ៨នៃប្រកាសលេខ............. ចុះថ្ងៃទី...... ខែ......... ឆ្នាំ២០... របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់។

**ប្រការ ៤.-**

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់អនុវត្តរបៀបរបបការងាររបស់ខ្លួន ដូចមានចែងក្នុងជំពូកទី៣នៃប្រកាសលេខ............. ចុះថ្ងៃទី...... ខែ......... ឆ្នាំ២០... របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់។

**ប្រការ ៥.-**

បទប្បញ្ញត្តិទាំងឡាយណារបស់រដ្ឋបាលឃុំ ឬសង្កាត់.............. ដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៦.-**

សមាជិកក្រុមប្រឹក្សាឃុំ ឬសង្កាត់.............. និងដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ......................ខែ...........ឆ្នាំ.................. ព.ស.២៥....

ធ្វើនៅ................. ថ្ងៃទី...... ខែ........... ឆ្នាំ២០....

**មេឃុំ ឬចៅសង្កាត់**

**__កន្លែងទទួល៖__**
- ដូចប្រការ១ និងប្រការ៦
- ឯកសារ កាលប្បវត្តិ

*ទម្រង់ទី២ ៖ សេចក្តីសម្រេចស្តីពីការតែងតាំងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ*

(*ក្បាលលិខិត*)

# សេចក្តីសម្រេច
## ស្តីពី
## ការតែងតាំងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ឬសង្កាត់............

**មេឃុំ ឬចៅសង្កាត់....................**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការផ្ទេរវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញប្រកាសលេខ............ ចុះថ្ងៃទី..... ខែ........ ឆ្នាំ២០... របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់
- បានទទួលការអនុម័តនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ ឬសង្កាត់............ នាថ្ងៃទី..... ខែ........ ឆ្នាំ២០...

# សម្រេច

**ប្រការ ១.-**

តែងតាំងលោក ឬលោកស្រី.................. ជា.........(*ជំទប់ទី២ ចៅសង្កាត់រងទី១ ឬ សមាជិកក្រុមប្រឹក្សា ឬមេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិនៃភូមិ..........*).......... ធ្វើជា**អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ឬសង្កាត់**............ នៃក្រុង ស្រុក ខណ្ឌ............... រាជធានី ខេត្ត...............។

**ប្រការ ២.-**

អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ឬសង្កាត់ មានតួនាទីជួយរដ្ឋបាលឃុំ ឬសង្កាត់ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ឬសង្កាត់លើកិច្ចការសេវាសង្គមទាំងអស់នៅក្នុងឃុំ ឬសង្កាត់ ................ និងមានភារកិច្ចដូចខាងក្រោម ៖

- ...........................................................................................................
- ...........................................................................................................
- ...........................................................................................................
- ...........................................................................................................
- ...........................................................................................................
- ...........................................................................................................
- ...........................................................................................................

**ប្រការ ៣.-**

អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវបានផ្តល់សិទ្ធិឱ្យចូលរួមកិច្ចពិភាក្សា ឬកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ លើកលែងតែសាមីខ្លួនជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។ *(ក្នុងករណីអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវលុបឃ្លានេះចេញ)*

អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ឬសង្កាត់ត្រូវបានផ្តល់សិទ្ធិឱ្យចូលរួមកិច្ចពិភាក្សា ឬកិច្ចប្រជុំរបស់គណៈកម្មាធិការនានារបស់រដ្ឋបាលឃុំ ឬសង្កាត់................ ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ លើកលែងតែសាមីខ្លួនជាសមាជិកនៃគណៈកម្មាធិការនោះ។

**ប្រការ ៤.-**

បទប្បញ្ញត្តិទាំងឡាយណារបស់រដ្ឋបាលឃុំ ឬសង្កាត់................ ដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៥.-**

សមាជិកក្រុមប្រឹក្សាឃុំ ឬសង្កាត់............... និងដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ.........................ខែ............ឆ្នាំ.......................ព.ស.២៥....

ធ្វើនៅ.................. ថ្ងៃទី...... ខែ............ ឆ្នាំ២០....

**មេឃុំ ឬចៅសង្កាត់**

**__កន្លែងទទួល ៖__**

- ដូចប្រការ១ និងប្រការ៥
- ឯកសារ កាលប្បវត្តិ

៨

*ទម្រង់ទី៣ ៖ សេចក្តីសម្រេចស្តីពីការតែងតាំងជំនួយការសេវាសង្គម*

(ក្បាលលិខិត)

**សេចក្តីសម្រេច**

**ស្តីពី**

**ការតែងតាំងជំនួយការសេវាសង្គមឃុំ ឬសង្កាត់.................**

**មេឃុំ ឬចៅសង្កាត់....................**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការផ្ទេរមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញប្រកាសលេខ............ ចុះថ្ងៃទី..... ខែ........ ឆ្នាំ២០... របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់
- បានទទួលការអនុម័តនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ ឬសង្កាត់............ នាថ្ងៃទី...... ខែ......... ឆ្នាំ២០...

**សម្រេច**

**ប្រការ ១.**

តែងតាំងលោក ឬលោកស្រី..................... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ.............. ដែលមានទីលំនៅបច្ចុប្បន្ននៅ............................................................. ជាជំនួយការសេវាសង្គមឃុំ ឬសង្កាត់............... នៃក្រុង ស្រុក ខណ្ឌ.................. រាជធានី ខេត្ត..............

**ប្រការ ២.-**

ជំនួយការសេវាសង្គមឃុំ ឬសង្កាត់មានតួនាទីជួយរដ្ឋបាលឃុំ ឬសង្កាត់ អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ ឬសង្កាត់ និងស្មៀនឃុំ ឬសង្កាត់លើកិច្ចការសេវាសង្គមទាំងអស់នៅក្នុងឃុំ ឬសង្កាត់.............. និងមានភារកិច្ចដូចខាងក្រោម៖

- .................................................................................................................
- .................................................................................................................
- .................................................................................................................
- .................................................................................................................
- .................................................................................................................
- .................................................................................................................
- .................................................................................................................
- .................................................................................................................
- .................................................................................................................
- .................................................................................................................
- .................................................................................................................

**ប្រការ ៣.-**

បទប្បញ្ញត្តិទាំងឡាយណារបស់រដ្ឋបាលឃុំ ឬសង្កាត់.............. ដែលផ្ទុយនឹងសេចក្ដីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៤.-**

សមាជិកក្រុមប្រឹក្សាឃុំ ឬសង្កាត់.............. និងដូចមានចែងក្នុងប្រការ១ខាងលើត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ........................ខែ............ឆ្នាំ..................ព.ស.២៥.....

ធ្វើនៅ................. ថ្ងៃទី...... ខែ.............ឆ្នាំ២០..

**មេឃុំ ឬចៅសង្កាត់**

**<u>កន្លែងទទួល</u> ៖**

- ដូចប្រការ១ និងប្រការ៤
- ឯកសារ កាលប្បវត្តិ

បោះពុម្ពដោយគម្រោងលើកកម្ពស់វិស័យសេវាសង្គម
គាំទ្រដោយយូនីសេហ្វ

unicef

for every child